ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភារដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៦២

ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០២១

**សាលដីកា**

លេខ ២៦ "ឃ"

ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០២២

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០២២ ។

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

១-ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២-លោកជំទាវ [redacted] ចៅក្រម

៣-ឯកឧត្តម [redacted] ចៅក្រម

៤-លោកជំទាវ [redacted] ចៅក្រម

៥-ឯកឧត្តម [redacted] ចៅក្រម

## ចៅក្រមទទួលបញ្ជា

លោកជំទាវ [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

- **ដើមចោទ** (ដើមបណ្តឹងសាទុក្ខ) ៖ ឈ្មោះ [redacted] ខាសេង ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៤៦០៦៤៥ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ មានទីលំនៅបច្ចុប្បន្ននៅផ្ទះ [redacted] ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។



Scanned with CamScanner

- **សហចុងចម្លើយ** (ចុងបណ្តឹងសាទុក្ខ)

១.ឈ្មោះ [redacted] សៅរ៍សេរីជា ភេទស្រី អាយុ ៣៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ។

២.ឈ្មោះ [redacted] សុកសួរមេត្តា ភេទប្រុស អាយុ ៣៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៤០៧០៥០ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១៤ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**កម្មវត្ថុបណ្តឹង ៖ ខ្លឹមសារនៃសាលក្រមដែលប្តឹងទាមទារដោយដើមចោទ ៖**

-ឱ្យចុងចម្លើយឈ្មោះ [redacted] សៅរ៍សេរីជា និងលោក [redacted] សុកសួរមេត្តា គោរពតាមកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ដោយឱ្យសងប្រាក់ដើមចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងប្រាក់ពិន័យចំនួនពីរដងនៃប្រាក់ដើម ។

-ស្នើសុំឱ្យអនុវត្តបណ្តោះអាសន្នលើប្រាក់ដើម ។

**កម្មវត្ថុបណ្តឹងតប ៖ ខ្លឹមសារនៃសាលក្រមដែលប្តឹងទាមទារដោយចុងចម្លើយតប ៖**

១-ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ ចោលជាអសារបង់ ។

២-សុំរំលាយកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៩ និងកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ព្រមទាំងសុំរឹបអូសប្រាក់ថ្លៃដីបង់រួចចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

៣-បង្គាប់ឱ្យចុងបណ្តឹងតបធ្វើការផ្ទេរកម្មសិទ្ធិលើលិខិតផ្ទេរសិទ្ធិលេខ ៧០១ មត ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ មកឱ្យដើមបណ្តឹងតបឈ្មោះ [redacted] សុកសួរមេត្តា និងឈ្មោះ [redacted] សៅរ៍សេរីជា ។

៤-បង្គាប់ឱ្យចុងបណ្តឹងតបប្រគល់អចលនទ្រព្យ(ដី) ទាំង ២ ប្លង់ដូចខាងក្រោម ៖

-ប្លង់ទី១ ៖ ដីទំហំ ៩៤០៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានព្រំប្រទល់ដូចខាងក្រោម ៖

ខាងជើងទល់នឹងថៅកែ ខាងត្បូងទល់នឹង [redacted] សៅរ៍សេរីជា

ខាងកើតទល់នឹង [redacted] ខាសេង ខាងលិចទល់នឹងទំនប់

-ប្លង់ទី២ ៖ ដីទំហំ ២៦៦៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានព្រំប្រទល់ដូចខាងក្រោម ៖

ខាងជើងទល់នឹង [redacted] សៅរ៍សេរីជា ខាងត្បូងទល់នឹង [redacted] សួលី

ខាងកើតទល់នឹង [redacted] ខាសេង ខាងលិចទល់នឹង ទំនប់



Scanned with CamScanner

៥-បង្គាប់ឱ្យចុងបណ្ដឹងតបជាអ្នកទទួលបន្ទុកលើពន្ធប្រថាប់ត្រា និងការចំណាយផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិដូចក្នុងចំណុចទី៣ ខាងលើ ។

៦-ទាមទារសំណងការខូចខាតផ្សេងៗ រួមទាំងសេវាមេធាវីចុងបណ្ដឹងតប ដោយគិតជាប្រាក់សរុបចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

## អង្គហេតុ និងចំណុចវិវាទ

### ក.អំពីអង្គហេតុជាមូលហេតុនៃការទាមទារ

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ របស់ដើមចោទឈ្មោះ [redacted] ខាសេង បានបញ្ជាក់ថា ៖ ខ្លួនបានទិញដីចំនួន ០២ ប្លង់ ដែលប្លង់ទី១ មានទំហំចំនួន ៩៤០៧ ម៉ែត្រការ៉េ និងប្លង់ទី២ មានទំហំដីចំនួន ២៦៦៧ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល តាមកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ដែលមានខ្លឹមសារតាមប្រការ ៖

ត្រង់ប្រការ ៤.១ ក្នុងរយៈពេលនេះ ភាគីលក់ ត្រូវផ្ដិតមេដៃបំពេញបែបបទ និងរត់លិខិតផ្ទេរសិទ្ធិកម្មសិទ្ធិចេញពីស្រុក ដែលមានការទទួលស្គាល់ពីអាជ្ញាធរចូលទៅបង់ពន្ធ ជូនទៅឱ្យភាគីអ្នកទិញ ដោយមានឈ្មោះភាគីអ្នកទិញត្រឹមត្រូវតាមច្បាប់ ។

ត្រង់ប្រការ ៤.៤ "ភាគីអ្នកទិញត្រូវប្រគល់ប្រាក់តាមប្រការ ៤.៣ យ៉ាងយូរ ១៥ថ្ងៃ ក្រោយពីភាគីលក់ជូនដំណឹងស្ដីពីការផ្ទេរកម្មសិទ្ធិចប់រួចរាល់"

ត្រង់ប្រការ ៤.៥ បានបញ្ជាក់ថា "ភាគីលក់ នឹងប្រគល់ឯកសារផ្ទេរសិទ្ធិកម្មសិទ្ធិ ដែលមានទីតាំង និងភិនភាគតាមប្រការ២ ខាងលើដោយមានឈ្មោះ ភាគីទិញជាម្ចាស់កម្មសិទ្ធិ ជូនទៅភាគីអ្នកទិញត្រឹមត្រូវតាមច្បាប់ លុះត្រាណាភាគីទិញបានប្រគល់ប្រាក់ផ្ដាច់ ១០០% តាមប្រការ ៤.៣" ។

ត្រង់ប្រការ ៧.៣ បានបញ្ជាក់ថា "ក្នុងករណីភាគីអ្នកលក់ ធ្វើការកែប្រែឈប់លក់ ឬ មិនអាចបំពេញលក្ខខណ្ឌតាមប្រការ ៥ បាននោះ ភាគីអ្នកលក់ ត្រូវសងការខូចខាតចំនួន ០២ ដង នៃប្រាក់ដែលខ្លួនបានទទួលឱ្យទៅភាគីអ្នកទិញ វិញដោយមិនតវ៉ា" ។

ក្នុងពេលអនុវត្ត ភាគីទិញបានប្រគល់ប្រាក់ចំនួន ២ លើក សរុប ១០០.០០០ USD (ដប់ម៉ឺនដុល្លារអាមេរិក) រួចហើយ ។

-ភាគីលក់ បានប្រគល់លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៩ ដែលចុះហត្ថលេខាដោយលោកអភិបាលស្រុក លេខ ៧០១ ម.ព ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ (ថតចម្លង) មកឱ្យភាគីទិញ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៩ ហើយ ខ្លួនបានយកទៅពិនិត្យ និងផ្ទៀងផ្ទាត់នៅចំពោះមុខសាលាស្រុកមុខកំពូល តាមសម្ដីអាជ្ញាធរស្រុកមុខកំពូលបានបញ្ជាក់ថា ឯកសារនេះមិនត្រូវត្រូវទេ

(នៅមានការចន្លោះប្រហោង) ។ ហើយអាជ្ញាធរស្រុកបានធ្វើការអញ្ជើញ ភាគីអ្នកលក់ ចំនួន ០៣ លើក មក ហើយ តែភាគីអ្នកលក់មិនព្រមចូលរួមសហការនោះទេ ។ គិតតែដាក់លិខិតទាមទារប្រាក់ ។

ដោយសារតែភាគីលក់មិនព្រមចូលខ្លួនមកដោះស្រាយចំពោះមុខអាជ្ញាធរស្រុក ដើម្បីកសាងឯកសារឱ្យបានត្រឹមត្រូវតាមច្បាប់ ហើយចេះតែអូសបន្លាយពេលវេលា ជាហេតុឱ្យខូចប្រយោជន៍ខ្លួន ។

តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០ របស់ចុងបណ្ដឹងតបឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា បានបញ្ជាក់ថា ៖ អចលនវត្ថុ (ដី) ចំនួន ២ ប្លង់ គឺ ទី១: ទំហំ ៩៤០៧ ម² និងទី២ ទំហំ ២៦៦៧ ម² មានទីតាំងជាប់គ្នានៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកខ្សាច់កណ្ដាល ពួកខ្លួនបានព្រមព្រៀងលក់ឱ្យចុងបណ្ដឹងតប ដោយបានធ្វើកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១ នៅក្នុងកិច្ចសន្យានេះគឺពួកខ្លួនជាម្ចាស់អលចទ្រព្យ (ដី) មានកាតព្វកិច្ចត្រូវរៀបចំឯកសារ គឺពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីត្រឹមសាលាស្រុកមុខកំពូល ហើយចុងបណ្ដឹងតបមានកាតព្វកិច្ចត្រូវទូទាត់ថ្លៃដីគ្រប់ចំនួនមកឱ្យពួកខ្លួនយ៉ាងយូរក្នុងរយៈពេល ១៥ថ្ងៃ ដូចមានចែងក្នុងប្រការ៤ ចំណុច ៤.៣ និងចំណុច ៤.៤ ។ ហើយមកដល់ពេលនេះពួកខ្លួនជាម្ចាស់ដី បានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចសន្យាទិញលក់ដីរួចរាល់ហើយ គឺបានរត់ការលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីត្រឹមសាលាស្រុកមុខកំពូល គឺលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ៧០១ មព ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ និងបានបង់ពន្ធជូនសាខាពន្ធដារខេត្តកណ្ដាលតាមបង្កាន់ដៃបង់ប្រាក់ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ ប៉ុន្តែចុងបណ្ដឹងតប បែរជាមិនបានបំពេញកាតព្វកិច្ចជាអ្នកទិញទូទាត់ប្រាក់ថ្លៃបង្គ្រប់មកឱ្យពួកខ្លួនតាមកិច្ចសន្យាទិញលក់ដី ទោះបីពួកខ្លួនបានជូនដំណឹងតាមរយៈទូរស័ព្ទដៃផង តាមរយៈ Telegram ផង ហើយក៏មានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៩,ជូនដំណឹងលើកចុងក្រោយ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៩ របស់មេធាវីពួកខ្លួន ចុងបណ្ដឹងតបនៅតែមិនអនុវត្ត ឬ ទូទាត់ថ្លៃដីបង្គ្រប់ ដោយដូច្នេះហើយពួកខ្លួនក៏បានជូនដំណឹងពីការរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៩ ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារ:**

ពួកខ្លួនជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ (ដី) ចំនួន ២ ប្លង់ គឺទី១ ទំហំ ៩៤០៧ ម² និងទី២ ទំហំ ២៦៦៧ ម² មានទីតាំងជាប់គ្នា នៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកខ្សាច់កណ្ដាល ដែលបានទិញពីប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រឹមត្រូវ ដោយបានធ្វើលិខិតបញ្ជាក់កម្មសិទ្ធិចុះហត្ថលេខទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានភូមិឃុំត្រឹមត្រូវ នៅក្នុងឆ្នាំ ២០១៥ (លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២១៤/១៥ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៧៣/១៥ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០១៥) ទើបមកដល់ឆ្នាំ ២០១៩ ពួកខ្លួនបានព្រមព្រៀងលក់ដីទាំង២ប្លង់នេះបន្តទៅឱ្យចុងបណ្ដឹងតបឈ្មោះ [redacted] ខាស៊េង ។ បន្ទាប់ពីចុងបណ្ដឹងតបបានចុះពិនិត្យមើលដីនិងសាកសួរភូមិឃុំរួចរាល់ហើយ ម្យ៉ាងទៀតដីរបស់ចុងបណ្ដឹងតបក៏មាននៅជាប់ក្រោយដីរបស់ពួកខ្លួនដែលបានលក់ឱ្យគាត់នេះដែរ ដូច្នេះគាត់បានដឹងពីប្រវត្តិដីនៅទីនោះច្បាស់

ជាងខ្លួនទៅទៀត ដូច្នេះហើយចុងបណ្តឹងតប បានព្រមព្រៀងធ្វើកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៩ និងបានព្រមព្រៀងគ្នាធ្វើការទូទាត់ជា ៣ ដំណាក់កាល ហើយចុងបណ្តឹងតបបានទូទាត់ប្រាក់លើកទី១ ចំនួន ៥០.០០០ USD (ប្រាំម៉ឺនដុល្លារអាមេរិក) និងនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ចុងបណ្តឹងតបបានរៀបចំកិច្ចព្រមព្រៀង ០១ ទៀត និងបានទូទាត់ប្រាក់ដំណាក់កាលទី ២ ចំនួន ៥០.០០០ USD (ប្រាំម៉ឺនដុល្លារអាមេរិក) ហើយនៅពេលដែលអាជ្ញាធររៀបចំផ្ទេរសិទ្ធិពីឈ្មោះពួកខ្លួនចូល និង ដាក់ឈ្មោះចុងបណ្តឹងតបឈ្មោះ [redacted] ខាសេង រួចរាល់ ចុងបណ្តឹងតប (អ្នកទិញ) ត្រូវប្រគល់ថ្លៃដីបង្គ្រប់ក្នុងរយៈពេល ១៥ ថ្ងៃ មកឱ្យពួកខ្លួន (អ្នកលក់) ។

មកដល់ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ ពួកខ្លួនបានបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកលក់ (ម្ចាស់ដី) ឬបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៩ និងកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ចប់សព្វគ្រប់អស់ហើយ ហើយក៏បានជូនដំណឹងតាមរយៈទូរស័ព្ទដៃផង តាមរយៈ Telegram ផង ជាលាយលក្ខណ៍អក្សរផង ប៉ុន្តែចុងបណ្តឹងតបមិនបានអនុវត្តកិច្ចសន្យា គឺទូទាត់ថ្លៃដីបង្គ្រប់មកពួកខ្លួននោះទេ ហេតុដូច្នេះហើយទើបពួកខ្លួនសម្រេចធ្វើលិខិតជូនដំណឹងអំពីរំលាយកិច្ចសន្យាចោលវិញ ។

- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៤ (ជជ) ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តកណ្តាល **ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ច្រានចោលការទាមទារទាំងអស់របស់សហចុងចម្លើយ និងជាសហដើមចោទនៃបណ្តឹងតប តាមពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០ ។

២-បង្គាប់ឱ្យសហចុងចម្លើយ និងជាសហដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា សងប្រាក់មកឱ្យដើមចោទឈ្មោះ [redacted] ខាសេង មានប្រាក់ដើមសរុបចំនួន USD ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

៣-បង្គាប់ឱ្យសហចុងចម្លើយ និងជាសហដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា សងប្រាក់ពិន័យចំនួន USD ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] ខាសេង ។

៤-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី២ នៃសេចក្តីសម្រេចបញ្ជាប់លើប្រាក់ដើមចំនួន USD ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ និងជាសហដើមចោទនៃបណ្តឹងតប ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ ។

ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។



Scanned with CamScanner

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១៨ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២០ របស់ឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤ (ជជ) ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ សាលដីការដ្ឋប្បវេណីលេខ ០៦ ក្រII (ញ) ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ច្រានពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២០ របស់ឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា ចោលជាអសាររបង់ ។

២.តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៤ "ជជ" ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ លើកលែងតែចំណុចទី ៣ នៃសេចក្តីសម្រេចត្រង់ឃ្លាថា "សងប្រាក់ដើមចំនួន ១០០.០០០ ដុល្លារអាមេរិក" ត្រូវកែប្រែមកជា "សងប្រាក់ការខូចខាតចំនួន ៧០ ០០០ ដុល្លារអាមេរិក វិញ" ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

៤.សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ ទុកសិទ្ធិឱ្យប្តឹងសាទុក្ខក្នុងរយៈពេលមួយខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

- បានឃើញ បណ្តឹងសាទុក្ខ លេខ ១១៣ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៦ ក្រII (ញ) ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ បណ្តឹងសាទុក្ខ លេខ ១៥៦ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២១ របស់ដើមចោទឈ្មោះ [redacted] ខាសេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៦ ក្រII (ញ) ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទី ២ នៃសេចក្តីសម្រេច ។

តំណាងមហាអយ្យការបានធ្វើសេចក្តីថ្លែងការណ៍ថា៖ នៅក្នុងរឿងក្តីនេះគូភាគីបានប្តឹងទាក់ទងនឹងការទាមទារសិទ្ធិលើដីដែលកើតឡើងពីកិច្ចសន្យាទិញលក់ យល់ឃើញថា ការទិញលក់នេះ គឺមានបញ្ហាកើតឡើងដោយសារការផ្ទេរកម្មសិទ្ធិដោយគូភាគីមានទំនាស់ឱ្យរំលាយកិច្ចសន្យាចោល កត់សម្គាល់ឃើញថា កម្មវត្ថុនៃការទិញដីនេះគឺពាក់ព័ន្ធនឹងទ្រព្យសម្បត្តិសាធារណៈ ដោយតែដីនៅទីនេះអាជ្ញាធរបានបង្ហាញថា អនុញ្ញាតឱ្យមានការកាន់កាប់អាស្រ័យផល ប៉ុន្តែមិនអាចចេញប័ណ្ណកម្មបានទេ ពីព្រោះដីនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងធនធានទឹក ។ សូមប្រធានក្រុមប្រឹក្សាមេត្តាស្វែរបញ្ជាក់ពីបញ្ហានេះដែលពាក់ព័ន្ធនឹងការទាមទារកម្មសិទ្ធិនៃដីប្រសិនបើមានការទិញលក់ទ្រព្យសម្បត្តិសាធារណៈមែន ។ សូមក្រុមប្រឹក្សាពិនិត្យ និងពិចារណា មុនសម្រេច

សេចក្ដីចុងក្រោយ ។ ដើម្បីផលប្រយោជន៍ដល់គូភាគី សូមក្រុមប្រឹក្សាមេត្តាពិចារណាតាមច្បាប់ភូមិបាល,កិច្ចសន្យាលក់ទិញ និងការអនុវត្តកាតព្វកិច្ច ។

### ខ.អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ទាក់ទងនឹងរឿងនេះ គឺជារឿងកិច្ចសន្យាពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាទិញលក់ដី ០២ កន្លែង មានកិច្ចសន្យាចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ។ កូនក្ដីរបស់ខ្លួនបានទិញដីពីម្ចាស់ដើមក្នុងឆ្នាំ ២០១៥ ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ២១៤/១៥ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៧៣/១៥ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០១៥ ដែលដីនេះពីដើមឡើយគឺបានទិញដោយមានលិខិតអាជ្ញាធរភូមិឃុំបញ្ជាក់ក្នុងឆ្នាំ ២០១៥ ។ កូនក្ដីរបស់ខ្លួនក៏បានធ្វើការបន្តលក់ទៅឱ្យលោក [redacted] ខាសេង នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ដែលនេះជាវិវាទរវាងគ្នានឹងគ្នាតាំងពីសាលាដំបូងខេត្តកណ្ដាលមក ។ ទាក់ទងនឹងកិច្ចសន្យានេះពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់កូនក្ដីរបស់ខ្លួនគឺបានត្រូវបំពេញកាតព្វកិច្ចនៅត្រឹមសាលាស្រុក គឺត្រូវធ្វើយ៉ាងណាកូនក្ដីរបស់ខ្លួនបំពេញកាតព្វកិច្ចផ្ទេរកម្មសិទ្ធិដែលហៅថា លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីទៅឱ្យឈ្មោះ [redacted] ខាសេង ។ ឈ្មោះ [redacted] ខាសេង ត្រូវតែទូទាត់លុយចុងក្រោយដែលជាដំណាក់កាលទី៣ មកឱ្យកូនក្ដីរបស់ខ្លួន ។ នៅក្នុងនីតិវិធីនៃការអនុវត្តនៃកិច្ចសន្យាកូនក្ដីរបស់ខ្លួនបានបំពេញកាតព្វកិច្ចដោយស្មោះសសុច្ចរិតជូនទៅភាគីអ្នកទិញ មានន័យថាកូនក្ដីរបស់ខ្លួនបានធ្វើការងាររបស់ខ្លួននៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកិច្ចសន្យារហូតបានដល់អាជ្ញាធរបានចេញលិខិត ផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជីលេខ ៧០១ មព ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ ។ សូមបញ្ជាក់ជូនឯកឧត្ដមប្រធានបន្ថែមទៀតថា លិខិតនេះមិនមែនធ្វើឡើងដោយមានការបន្លំទេ ក្នុងលំហូរនីតិវិធីនៃការកសាងមានការបង្កើតគណៈកម្មការដែលបានដាក់ភស្តុតាងជូនរួចហើយ គ្រប់ដំណាក់កាលមានការចុះវាស់វែងត្រូវបានអាជ្ញាធរភូមិឃុំ ស្រុក និងបានប្រថាប់ត្រាជាផ្លូវការរបស់ឃុំ ស្រុក រួចរាល់ហើយ ។ នៅក្នុងដីកូនក្ដីរបស់ខ្លួនគឺនៅជាប់ផ្លូវ ដោយឡែកដីរបស់លោក [redacted] ខាសេង នៅខាងក្រោយ ហើយចង់ទិញរបស់កូនក្ដីខ្លួនដើម្បីបើកផ្លូវ ដូច្នេះឈ្មោះ [redacted] ខាសេង បានដឹងពីប្រវត្តិ និងទីតាំងនៃដីនេះច្បាស់លាស់អស់ហើយ ទើបបានធ្វើកិច្ចសន្យាផ្ទេរត្រឹមសាលាស្រុក ។ ចំណុចទាំងអស់ដែលមានចែងក្នុងកិច្ចសន្យាកូនក្ដីខ្លួនបានបំពេញរួចហើយ និងថែមទាំងបានជូនដំណឹងទៅឈ្មោះ [redacted] ខាសេង ប៉ុន្តែឈ្មោះ [redacted] ខាសេង មិនព្រមអនុវត្តកាតព្វកិច្ចទើបធ្វើឱ្យមានរឿងកើតឡើង ។ អ្វីដែលលោក ឈុន ខាសេង បានធ្វើគឺផ្ទុយនឹងកិច្ចសន្យា ។ ត្រឡប់មកវិញការបំពេញកាតព្វកិច្ចរបស់កូនក្ដីខ្លួនគឺត្រឹមត្រូវគ្រប់គ្រាន់ហើយ ។ម្យ៉ាងវិញទៀត យោងតាមមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណី (ករណីយកិច្ចអ្នកលក់ និងអ្នកទិញ) ។ ចំណុចមួយទៀត សូមតុលាការពិនិត្យភស្តុតាង ថាដីនេះជាដីសាធារណៈ ហើយលោក [redacted] ខាសេង បានដឹងរួចហើយថាជាដីរបស់ធនធានទឹក សួរថាបើជាដីសាធារណៈតើអានុភាពនៃកិច្ចសន្យាអាចអនុវត្តបានដែរឬទេ? បើតាមច្បាប់បើដីជាសាធារណៈ គឺពុំអាចធ្វើទៅបានទេ ។ តុលាការសាលាដំបូងខេត្តកណ្ដាល និងសាលាឧទ្ធរណ៍មិនបានពិនិត្យថា កិច្ចសន្យារបស់ភាគីបានដឹងពីស្ថានភាព

ដីទីតាំងដីយ៉ាងមេច ដោយដីនេះអាចមានពាក់ព័ន្ធនឹងធនធានទឹក មានន័យថា ភាគីដឹងរួចហើយថា ជាដីវិវាទសាធារណៈ ។ កិច្ចសន្យាបានបង្កើតរួចហើយ ប្រសិនបើកិច្ចសន្យាទាក់ទងនឹងវិវាទសាធារណៈ តើអាចយកមកអនុវត្តបានរឺទេ? មានន័យថា កិច្ចសន្យានេះអត់មានអានុភាពតាំងពីដើមមកម្លេះ គឺគ្រាន់តែចែងមកដើម្បីបំពេញកាតព្វកិច្ច ។ សូមក្រុមប្រឹក្សាពិនិត្យពាក់ព័ន្ធនឹងកិច្ចសន្យា ។ ចំណុចមួយទៀត បណ្តឹងសាទុក្ខរបស់ភាគីឈ្មោះ [redacted]ខាសេង ការប្តឹងសាទុក្ខមកតុលាការកំពូល គឺផ្ទេះសិទ្ធិរួចហើយ ដោយច្បាប់បានកំណត់រយៈពេល ១ ខែ ។

សំណូមពរៈ សូមឯកឧត្តមប្រធានក្រុមប្រឹក្សាច្រានចោលបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខឈ្មោះ [redacted] ខាសេង ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ខាសេង បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីខ្លួនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរួចហើយ ដោយបានបញ្ជាក់ថា [ កូនក្តីខ្លួនពិតជាបានទិញដីពីឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា តាមកិច្ចសន្យា ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ។ កិច្ចសន្យាកូនក្តីខ្លួនបានកក់លុយរហូតដល់ ៥០% ] ។ មេធាវីរបស់លោកស្រី [redacted] សៅរ៍សេរី និង [redacted] សុកសួរមេត្តា បានលើកឡើងថា ដីនេះជាដីសាធារណៈគឺហាក់បីដូចជាកូនក្តីឆ្គួតអញ្ចឹង បើដឹងថាជាដីសាធារណៈហើយ ទៅចុះកិច្ចសន្យាទិញធ្វើអ្វី ហើយកូនក្តីខ្លួនកក់ប្រាក់រហូតដល់ទៅ ៥០% ។ រឿងក្តីកើតឡើងដោយសារ តែក្នុងកិច្ចសន្យានៅពេលដែលភាគីអ្នកលក់ផ្ទេរឈ្មោះបានត្រូវប្រគល់ឯកសារមកឱ្យកូនក្តីខ្លួនពិនិត្យភាពត្រឹមត្រូវ នៃច្បាប់ ។ កូនក្តីខ្លួនយល់ឃើញថាត្រឹមត្រូវហើយ ទើបប្រគល់លុយគ្រប់ ១០០% ប៉ុន្តែផ្ទុយទៅវិញកូនក្តីខ្លួនបានយកឯកសារទៅពិនិត្យ និងផ្ទៀងផ្ទាត់នៅចំពោះមុខសាលាស្រុក ប៉ុន្តែបែរមន្ត្រីស្រុកថា ឯកសារមិនត្រឹមត្រូវ មិនពេញលេញ ចន្លោះប្រហោង ។ តាមកិច្ចសន្យាភាគីអ្នកលក់ត្រូវមានកាតព្វកិច្ចទៅដោះស្រាយជាមួយមន្ត្រីដើម្បីកសាងឯកសារឱ្យបានត្រឹមត្រូវតាមច្បាប់ច្បាស់លាស់ ។ កូនក្តីខ្លួនបានជូនដំណឹងចំនួន ០៣ លើកដើម្បីឱ្យទៅកែសម្រួលជាមន្ត្រីស្រុកឱ្យបានត្រឹមត្រូវ ប៉ុន្តែឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា គេចវេសមិនព្រមទៅថែមបានជេរប្រមាថនៅកូនក្តីខ្លួន និងមន្ត្រីថ្នាក់ស្រុកទៀតផង ទើបខាងមន្ត្រីស្រុកបានចេញកំណត់ហេតុបញ្ជាក់ថា ដីនេះនៅមានចន្លោះប្រហោង ។ ខាងភាគីអ្នកលក់គិតតែពីបង្ខំទាមទារប្រាក់ និងបង្ខំទាមទារឱ្យផ្តាច់ប្រាក់កក់ ៥០% ទើបកូនក្តីខ្លួនដាក់បណ្តឹងទៅតុលាការដើម្បីទាមទារប្រាក់កក់ ការខូចខាត និងរំលាយកិច្ចសន្យា ។ តុលាការខេត្តកណ្តាលបានសម្រេចចេញសាលក្រមយ៉ាងត្រឹមត្រូវទៅតាមច្បាប់ ព្រោះនៅក្នុងកិច្ចសន្យាបញ្ជាក់រួចហើយថា ប្រសិនបើមិនបានបំពេញកាតព្វកិច្ចត្រូវសងកូនក្តីខ្លួនចំនួន ១ គុណនឹង ២ ។ ដូច្នេះសាលក្រមរបស់សាលាដំបូងខេត្តកណ្តាលពិតជាត្រឹមត្រូវ ប៉ុន្តែភាគីបានប្តឹងឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍បានសម្រេចកែប្រែប្រាក់សំណងនៃការខូចខាតពី ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក មកត្រឹម ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ឃើញថា នេះជាការសម្រេចដែលធ្វើឱ្យខាតបង់ផលប្រយោជន៍របស់កូនក្តីខ្លួន ដែលជាការសម្រេចផ្ទុយនឹងច្បាប់ ផ្ទុយនឹងកិច្ចសន្យា ។ ច្បាប់ក៏បានកំណត់ និងកិច្ចសន្យាក៏បានកំណត់ឱ្យសងគុណនឹងពីរ ហើយកិច្ចសន្យានេះគឺជាច្បាប់របស់គូភាគី បានកំណត់ថាបើធ្វើមិនបានគឺត្រូវសងកូនក្តីខ្លួនចំនួន



Scanned with CamScanner

គុណនឹង ២ ។ ដូច្នេះ កូនក្តីខ្លួនបានធ្វើបណ្តឹងសាទុក្ខបន្ទាប់បន្សំទាមទារចំណុចឡើងវិញ ខាងខ្លួនទទួលស្គាល់ថា ការប្តឹងសាទុក្ខហួសរយៈពេលកំណត់មែន ប៉ុន្តែច្បាប់ពុំបានកំណត់បណ្តឹងបន្ទាប់បន្សំនោះទេ ។ កូនក្តីខ្លួនធ្វើបណ្តឹងបន្ទាប់បន្សំទាមទារនូវចំណុចការខូចខាត ។ កូនក្តីខ្លួនមានការខាតបង់ ទើបប្តឹងទាមទារតាមរយៈបណ្តឹងបន្ទាប់បន្សំនេះ ។ កូនក្តីខ្លួនមានដីនៅក្បែរនោះដែរ ។ ពីមុនមកកូនក្តីខ្លួនក៏មានការទិញដីពីប្រជាពលរដ្ឋមុនក៏មានការចុះហត្ថលេខាពីសាលាស្រុក ដោយអត់មានអ្នកណាដឹងទេថា ដីនេះពីមុនមកជាដីមេទឹក ។ អ្វីដែលកូនក្តីខ្លួនមិនអាចទទួលយកបានគឺ ខាងមន្ត្រីស្រុកបានបញ្ជាក់ថា ឯកសារដែលបានចុះហត្ថលេខាកន្លងមកមានការចន្លោះប្រហោង ហើយកូនក្តីខ្លួនប្រាប់ថា ឱ្យមកបំពេញត្រង់ភាពចន្លោះប្រហោងហ្នឹងទៅ គឺកូនក្តីខ្លួនយកដីនេះហើយ ។

-លោក[redacted]បានធ្វើសេចក្តីថ្លែងការតបថា ៖ តាមការពិតមានកិច្ចសន្យាចំនួន០២ ដោយកិច្ចសន្យាទី ១ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៩ ដោយកិច្ចសន្យាទី១ បានបង្ហាញឆន្ទៈភាគីបានដឹងទីតាំងដីច្បាស់លាស់រួចហើយ ក្នុងករណីផ្លូវច្បាប់ឯកសាររកមិនបានភាគីអ្នកលក់ ភាគីអ្នកលក់គួរសងប្រាក់ថ្លៃដើមវិញ មានន័យថាគាត់បានដឹងពីការសារបាននៃការធ្វើឯកសារនេះរួចហើយ ។ ដីរបស់លោក [redacted] ខាសេង នៅខាងក្រោយគោលបំណងដែលគាត់ទិញដីនេះគឺដើម្បីបើកផ្លូវ ។ កូនក្តីរបស់ខ្លួនបានទៅជួបនិងរដ្ឋបាលពាក់ព័ន្ធទៅនឹងការផ្ទេរ ។ នៅពេលដែលចុះកិច្ចសន្យារួចហើយ កូនក្តីខ្លួនបានជូនដំណឹងទៅលោក [redacted] ខាសេង ប៉ុន្តែបែរជាគាត់បដិសេធរហូតដល់មានការជូនដំណឹងតាមរយៈទូរស័ព្ទ ។ អ្វីដែលកូនក្តីខ្លួនបានបំពេញគឺដោយស្មោះសរ ដោយសុច្ចរិតក្នុងការបំពេញកិច្ចសន្យា ។

សំណូមពរ៖ សុំឯកឧត្តមប្រធានមេត្តាច្រានចោលបណ្តឹងសាទុក្ខ របស់ឈ្មោះ [redacted] ខាសេង ។

- លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបថា ៖ ខ្លួនបានចុះទៅព្យាយាមសម្រុះសម្រួលជាមួយគូភាគី ។ ពេលទៅដល់សាលាស្រុក ខាងសាលាស្រុកបានកោះហៅភូមិ ឃុំ និងអញ្ជើញខាងភាគីចូលមក ប៉ុន្តែភាគីអ្នកលក់អត់ព្រមអញ្ជើញមកទេ ។ លោកអភិបាលស្រុករងបានទូរស័ព្ទទៅទៀត ប៉ុន្តែគាត់បែរជេរប្រមាថថែមទៀត ។ ភាពចន្លោះប្រហោងនោះដោយសារតែមន្ត្រីដែលរត់ការដោយយកទីតាំងដីកន្លែងផ្សេងភ្ជាប់ឯកសារទៅឱ្យចៅហ្វាយស្រុកស៊ីញ៉េ ដែលនេះជាភាពចន្លោះប្រហោង ។ ខាងស្រុកបានព្យាយាមប្រាប់ឱ្យធ្វើត្រឹមត្រូវយកឱ្យត្រូវទីតាំងដី ព្រមទាំងហៅឱ្យមកសម្របសម្រួលគ្នា ប៉ុន្តែគាត់មិនព្រមចូលរួមទេ ម្តងហើយ ម្តងទៀត ទើបមានកំណត់ហេតុដល់ទៅ ២ ដង ដែលខ្លួនបានដាក់ជូននៅតុលាការរួចហើយ ។ ចំពោះត្រង់ថា ដីនេះ ជាដីមេទឹក កូនក្តីខ្លួនមិនដឹងថាជាដីមេទឹកពីមុនមកទេ ដឹងត្រឹមថាជាដីធ្វើស្រែជារៀងរាល់ឆ្នាំប៉ុណ្ណោះ ។ អ្វីដែលកូនក្តីខ្លួនមិនអាចទទួលយកបានគឺនៅត្រង់ស្រុកបញ្ជាក់ថា ឯកសារនៅមានចន្លោះប្រហោង ។ នៅពេលមានបញ្ហាកើតឡើងទើបខាងស្រុកបញ្ជាក់ថាជាដីមេទឹក ។ កូនក្តីខ្លួនក៏បានសួរទៅកាន់ស្រុកថា ប្រសិនបើជាដីមេទឹក ហេតុអ្វីក៏ដាក់ឯកសារស៊ីញ៉េបាន? ខាងស្រុកឆ្លើយថា យកឯកសារដីកន្លែងផ្សេងឱ្យគាត់ស៊ីញ៉េ ទើបគាត់មានការភាន់ច្រឡំដូច្នេះទើបហៅឱ្យមកដោះស្រាយជាមួយគ្នា ។ ដីនេះជាដីដែលមានវិការៈ បែរជាមកលក់ឱ្យកូនក្តីខ្លួន ដូច្នេះកូនក្តី

ខ្លួនមិនអាចប្រគល់លុយឱ្យគ្រប់ចំនួនបានទេ បើខាងអ្នកលក់មិនព្រមមកដោះស្រាយឱ្យដាច់ស្រលះជាមួយខាងស្រុក ។ ប៉ុន្តែខាងអ្នកលក់គិតតែចេញលិខិតផ្តាច់ប្រាក់កក់ៗរហូត ។

**សំណូមពរ៖** ខ្លួនសំណូមពរសុំឱ្យដូចតាមលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ខាសេង បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួនឯកភាពតាមសហភាគា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ហា

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

**១-យល់ឃើញថា** បណ្តឹងសាទុក្ខ លេខ ១១៣ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសូរមេត្តា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ២៨៣ និងមាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**២-យល់ឃើញថា** បណ្តឹងសាទុក្ខ លេខ ១៥៦ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] ខាសេង បានធ្វើឡើង បន្ទាប់ពីមេធាវីឈ្មោះ [redacted] លីដា បានទទួលសាលដីកានៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០២១ (ឯកសារលេខ ៣៨/០២) ដូច្នេះ គឺហួសអំឡុងពេលប្តឹងសាទុក្ខ ស្របតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវអនុវត្តដូចគ្នាចំពោះករណីបណ្តឹងសាទុក្ខ យោងតាមមាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែនាពេលទាញហេតុដោយផ្ទាល់មាត់នៅតុលាការកំពូល មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ខាសេង បានបញ្ជាក់ថា បណ្តឹងសាទុក្ខនេះគឺជាបណ្តឹងសាទុក្ខបន្ទាប់បន្សំ ហេតុដូច្នេះ តុលាការកំពូលអាចលើកយកមកពិចារណាក្នុងក្របខ័ណ្ឌជាបណ្តឹងសាទុក្ខបន្ទាប់បន្សំ តាមបទប្បញ្ញត្តិនៃមាត្រា ២៧០ និងមាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៣-យល់ឃើញថា** សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចសេចក្តីដោយផ្អែកលើប្រការ ៧.៣ នៃកិច្ចសន្យាដែលបានកំណត់អំពីកាតព្វកិច្ចរបស់គូភាគី ហើយភាគីអ្នកលក់មិនអាចបំពេញលក្ខខណ្ឌតាមប្រការ ៥ នោះភាគីអ្នកលក់ត្រូវសងការខូចខាតចំនួន ២ ដង នៃប្រាក់ដែលខ្លួនបានទទួលបាន ប៉ុន្តែសាលាឧទ្ធរណ៍ភ្នំពេញបន្ថយចំនួនសំណងនៃការខូចខាតខ្លះ ដោយយល់ឃើញថា ភាគីចុងចម្លើយបានបំពេញកាតព្វកិច្ចរបស់ខ្លួនបានមួយផ្នែកហើយ

តែចុងចម្លើយមានកំហុសត្រង់មិនបានចូលរួមទៅដោះស្រាយភាពចន្លោះប្រហោងលើលិខិតផ្ទេរសិទ្ធិដែលខ្លួនបានបំពេញរួចហើយនោះ តាមការកោះអញ្ជើញរបស់អាជ្ញាធរស្រុកមុខកំពូលដែលបានចេញលិខិតផ្ទេរសិទ្ធិនោះទេ ។

ចំពោះការសម្រេចសេចក្ដីយ៉ាងដូច្នេះ តុលាការកំពូលពិនិត្យឃើញថា ៖

-តាមកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ រវាងគូភាគី នៅត្រង់ប្រការ ៧.៣ នៃកិច្ចសន្យា នៅត្រង់វាក្យខណ្ឌទី ២ បានបញ្ជាក់ថា ក្នុងករណីភាគី “ក” ធ្វើការកែប្រែឈប់លក់ ឬ មិនអាចបំពេញលក្ខខណ្ឌ តាមប្រការ ៥ បាននោះ ភាគី “ក” ត្រូវសងការខូចខាតចំនួន ២ដង នៃប្រាក់ដែលខ្លួនបានទទួលឱ្យទៅភាគី “ខ” វិញ ដោយមិនតវ៉ា ។

-តាមកំណត់ហេតុ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១៩ ដែលបានធ្វើនៅការិយាល័យលោកអភិបាលរងស្រុក បង្ហាញឱ្យឃើញថា ដើមចោទបានឆ្លើយថា មុននឹងទិញដីខាងលើនេះ ខ្លួនបានចុះដល់ទីតាំងដី និងបានដឹងថាដីនេះ ពិតជាស្ថិតនៅក្នុងមេទឹកអំពៅខៀប ។ ម្យ៉ាងទៀត តាមកំណត់ហេតុដដែលនេះ ប្រធានអង្គប្រជុំបានបញ្ជាក់ថា ការទិញលក់ដីនៅចំណុចខាងលើ អាជ្ញាធរមិនមានការហាមឃាត់ទេ ប្រជាពលរដ្ឋដែលកាន់កាប់ដីនៅទីនេះអាច អាស្រ័យផលបាន និងមិនអាចចេញប័ណ្ណកម្មសិទ្ធិជូនបានទេ ព្រោះស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួង ធនធានទឹក និងឧតុនិយម ។

ដូច្នេះឃើញថា ដើមចោទបានដឹងថាដីដែលខ្លួនព្រមព្រៀងទិញពីសហចុងចម្លើយ គឺជាដីស្ថិតនៅក្នុង មេទឹកអំពៅខៀប ហើយដើមចោទក៏មានដីដែលមានព្រំប្រទល់ជាប់នឹងដីដែលជាកម្មវត្ថុនៃវិវាទក្នុងសំណុំរឿងនេះដែរ ហេតុនេះ ដើមចោទបានដឹងពីស្ថានភាពគតិយុត្តនៃដីដែលជាកម្មវត្ថុនៃការលក់ទិញនោះយ៉ាងប្រាកដ ។

-តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ២១៤/១៥ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ រវាងឈ្មោះ [redacted] សុខហេង និងឈ្មោះ [redacted] សៅរ៍សេរីជា ឈ្មោះ [redacted] សុកសួរមេត្តា ចុះហត្ថលេខាបញ្ជាក់ដោយមេឃុំសំបួរមាស និងគំនូសបង្ហាញទ្រង់ទ្រាយដីរបស់ឈ្មោះ[redacted]សៅរ៍សេរីជា ដែលទិញពីឈ្មោះ[redacted] យ៉ុន ចុះហត្ថលេខាបញ្ជាក់ដោយមេឃុំសំបួរមាស ឃើញថា សហចុងចម្លើយបានធ្វើលទ្ធកម្មលើដីដែលជាកម្មវត្ថុនៃវិវាទ ដោយមានការដឹងឮពីអាជ្ញាធរមូលដ្ឋាន ។

-យោងតាមលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ៧០១ ម.ព ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ រវាងឈ្មោះ [redacted] សុកសួរមេត្តា ឈ្មោះ[redacted]សៅរ៍សេរីជា និងឈ្មោះ [redacted] ខាសេង ឃើញថា មានការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីប្រភេទដីស្រែប្រាំង ដែលមានផ្ទៃសរុប ១២៨៣០ ម៉ែត្រការ៉េ ដែលត្រូវបានចុះហត្ថលេខាដោយមេឃុំ និងអភិបាលស្រុកមុខកំពូល ព្រមទាំងត្រូវបានបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ ដូចមានលិខិតបញ្ជាក់លេខ ១៧៦៥៨ អពដ.សខ.គណ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩ របស់សាខាពន្ធដារខេត្តកណ្ដាល បន្ទាប់ពីត្រូវបានវាស់វែងដោយគណៈកម្មការ តាមកំណត់ហេតុស្ដីពីការចុះពិនិត្យវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៩ ។

ហេតុដូច្នេះឃើញថា ដើមចោទបានបំពេញករណីយកិច្ចរបស់ខ្លួនស្របតាមប្រការ ៥.១ នៃកិច្ចសន្យាចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ រួចហើយ ក៏ប៉ុន្តែបន្ទាប់មកទើបអាជ្ញាធរស្រុកមុខកំពូលបញ្ជាក់ថា លិខិតផ្ទេរសិទ្ធិកាន់កាប់ខាងលើមានការចន្លោះប្រហោង ដោយមិនបានបង្ហាញថា មានការចន្លោះប្រហោងនៅត្រង់ណាឱ្យច្បាស់នោះទេ ដែលជាហេតុនាំឱ្យដើមចោទបដិសេធមិនបង់ប្រាក់បង្គ្រប់តាមកិច្ចសន្យា ។

យោងតាមសំអាងហេតុខាងលើនេះ បញ្ជាក់ឱ្យឃើញថា សហចុងចម្លើយបានបំពេញករណីយកិច្ចតាមកិច្ចសន្យារួចហើយ ក៏ប៉ុន្តែដោយហេតុថា ដីដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាដីស្ថិតនៅក្នុងមេទឹកអំពៅខ្មៅ ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងធនធានទឹក និងឧតុនិយម ពោលគឺមានការពាក់ព័ន្ធនឹងដីរបស់រដ្ឋដោយដើមចោទក៏បានដឹងពីស្ថានភាពគតិយុត្តនេះដែរ ដូច្នេះហើយទើបមានបញ្ហាកើតឡើងដែលមិនអាចឱ្យកិច្ចសន្យាលក់ទិញរវាងគូភាគីអនុវត្តបានចប់សព្វគ្រប់ ។

ហេតុដូចនេះ ការដែលតុលាការអង្គហេតុលើកឡើងពីកំហុសរបស់សហចុងចម្លើយដើម្បីអនុវត្តប្រការ ៧.៣ នៃកិច្ចសន្យា ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ គឺជាការមិនត្រឹមត្រូវទេ ។

**៤-យល់ឃើញថា** ការដែលសហចុងចម្លើយបានប្តឹងសាទុក្ខប្រឆាំងនឹងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្តាលដែលបានសម្រេចច្រានចោលការទាមទាររបស់សហចុងចម្លើយ តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០ នោះជាការមិនត្រឹមត្រូវទេ ពីព្រោះថា ៖

-យោងតាមសំអាងហេតុត្រង់ចំណុចទី ៣ ខាងលើ បង្ហាញឱ្យឃើញថា ដើមចោទមិនមានកំហុសក្នុងការមិនអនុវត្តករណីយកិច្ចបង់ប្រាក់បង្គ្រប់ តាមកិច្ចសន្យារបស់គូភាគីឡើយ ។ ដូចនេះ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដូចមានចែងក្នុងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី និងលក្ខខណ្ឌនៃការទាមទារសំណងនៃការខូចខាតតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី មិនត្រូវបានបំពេញឡើយ ។

-តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញឱ្យឃើញថា ដីដែលជាកម្មវត្ថុនៃកិច្ចសន្យារវាងគូភាគីមានការពាក់ព័ន្ធនឹងដីដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងធនធានទឹក និងឧតុនិយម ដែលជាដីរបស់រដ្ឋ ហេតុដូច្នេះ ការទាមទារឱ្យធ្វើការផ្ទេរកម្មសិទ្ធិ ឬ ប្រគល់ដីដូចខាងលើនេះ រវាងគូភាគី មិនអាចត្រូវបានទទួលស្គាល់នោះទេ ហើយលិខិតផ្ទេរសិទ្ធិពាក់ព័ន្ធផ្សេងៗក៏មិនអាចមានអានុភាពគតិយុត្តដែរ ស្របតាមមាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី ។

**៥-យល់ឃើញថា** អង្គហេតុនៅក្នុងរឿងក្តីនេះមានលក្ខណៈស្ថាពរហើយ ដូច្នេះ តុលាការកំពូលអាចសម្រេចសេចក្តីដោយខ្លួនឯងបាន តាមមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

យោងតាមសំអាងហេតុរៀបរាប់ខាងលើបង្ហាញឱ្យឃើញថា ដើមចោទបានបង់ប្រាក់ចំនួន ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ឱ្យសហចុងចម្លើយ ដោយផ្អែកលើការលក់ទិញ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៩ និងកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៩ ក៏ប៉ុន្តែកិច្ចសន្យានេះមិនអាចអនុវត្តបានចប់សព្វគ្រប់ ដោយមូលហេតុថា មានការពាក់ព័ន្ធនឹងដីរបស់រដ្ឋ ។ ហេតុដូច្នេះ សហចុងចម្លើយដែលបានទទួលប្រាក់ចំនួន ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ពីដើមចោទ មានករណីយកិច្ចត្រូវសងតាវលិកនេះទៅឱ្យដើមចោទវិញ ស្របតាមមាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី ។

៦-យល់ឃើញថា បណ្តឹងសាទុក្ខរបស់សហចុងចម្លើយមានមូលហេតុខ្លះនៃបណ្តឹងសាទុក្ខ តាមមាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ចំណែកឯបណ្តឹងសាទុក្ខបន្ទាប់បន្សំរបស់ដើមចោទ មិនមានមូលហេតុនៃបណ្តឹងសាទុក្ខ ដូចមានចែងនៅមាត្រា ២៨៤ និងមាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ។

៧-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៦ ក្រII (ញ) ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ ។

៨-យល់ឃើញថា តាមមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគីក្នុងចំណែកស្មើគ្នា ។

**ហេតុដូច្នេះ**

**សម្រេច**

**១.ច្រានចោល** ផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ១១៣ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា ។

**២.ច្រានចោល** បណ្តឹងសាទុក្ខលេខ ១៥៦ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] ខាសេង ។

**៣.បដិសេធ** សាលដីការដ្ឋប្បវេណីលេខ ០៦ ក្រII (ញ) ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងសាលក្រមរដ្ឋប្បវេណីលេខ ១៤ "ជជ" ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តកណ្តាល ដោយសម្រេចជាថ្មីដូចខាងក្រោម ៖

៣.១. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សៅរ៍សេរីជា និងឈ្មោះ [redacted] សុកសួរមេត្តា បង់ប្រាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ឱ្យដើមចោទឈ្មោះ [redacted] ខាសេង ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣.២.ច្រានចោលការទាមទាររបស់សហចុងចម្លើយ តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០ ។



Scanned with CamScanner

៤.ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់គូភាគីក្នុងចំណែកស្មើគ្នា ។

សាលដីកានេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០២២ ។

**ក្រុមប្រឹក្សាជំនុំជម្រះ**

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោកជំទាវ | | ចៅក្រម |
| ឯកឧត្តម | | ចៅក្រម |
| លោកជំទាវ | | ចៅក្រម |
| ឯកឧត្តម | | ចៅក្រម |
| កញ្ញា | | ក្រឡាបញ្ជី |

............................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner